ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៧៤០២.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតភូមិ នៃខេត្តពោធិ៍សាត់

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋបាលខេត្តពោធិ៍សាត់

### សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត **ភូមិបរវង្ស** ដោយបំបែកចេញពីភូមិទួលគ្រួស នៃសង្កាត់ចំរើនផល ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

ត្រូវបានបង្កើត **ភូមិផ្ទះព្រៃ** ដោយបំបែកចេញពីភូមិពាលញែក១ នៃសង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

ត្រូវបានបង្កើត **ភូមិសំពៅមាស** ដោយបំបែកចេញពីភូមិពាលញែក២ នៃសង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

ត្រូវបានបង្កើត **ភូមិចំការចេក** ដោយបំបែកចេញពីភូមិចំការចេកខាងជើង នៃសង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

ត្រូវបានបង្កើត **ភូមិថ្មបីដុំ** ដោយបំបែកចេញពីភូមិអូរថ្កូវ នៃសង្កាត់លលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

ត្រូវបានបង្កើត **ភូមិអូរក្រាវ** ដោយបំបែកចេញពីភូមិលលកស នៃសង្កាត់លលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

ត្រូវបានបង្កើត **ភូមិឈើទាលរូង** ដោយបំបែកចេញពីភូមិព្រៃឱម៉ាល់ នៃសង្កាត់លលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

**ប្រការ ២.-**

ត្រូវបានបង្កើត **ភូមិតាម៉ៅ** ដោយបំបែកចេញពីភូមិព្រែកត្របែក នៃឃុំកញ្ចរ ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។

ត្រូវបានបង្កើត **ភូមិប្រឡាយធំ** ដោយបំបែកចេញពីភូមិទួលទទឹង នៃឃុំកញ្ចរ ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។

**ប្រការ ៣.-**

ត្រូវបានបង្កើត **ភូមិព្រាល** ដោយបំបែកចេញពីភូមិនិគមន៍លើ នៃឃុំស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ប្រការ ៤.-**

ត្រូវបានបង្កើត **ភូមិស្រង់** ដោយបំបែកចេញពីភូមិក្រឡាញ់ នៃឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់។

ត្រូវបានបង្កើត **ភូមិក្រាំងខៀន** ដោយបំបែកចេញពីភូមិផ្ទះរចេក និងភូមិឈើទែប នៃឃុំឈើតុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់។

**ប្រការ ៥.-**

ត្រូវបានបង្កើត **ភូមិគោ** ដោយបំបែកចេញពីភូមិអង្រ្កង នៃឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

ត្រូវបានបង្កើត **ភូមិអូរ** ដោយបំបែកចេញពីភូមិប្រងិល នៃឃុំប្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

ត្រូវបានបង្កើត **ភូមិព្រៃអណ្ដូង** ដោយបំបែកចេញពីភូមិអូរបោកត្រា នៃឃុំប្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

**ប្រការ ៦.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលភូមិបង្កើតថ្មីដូចមានចែងនៅក្នុងប្រការ១ ប្រការ២ ប្រការ៣ ប្រការ៤ និងប្រការ៥ នៃប្រកាសនេះ ត្រូវអនុលោមទៅតាមសេចក្តីណែនាំលេខ ០០៥ សជណន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្តីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាខេត្តពោធិ៍សាត់ គណៈអភិបាលខេត្តពោធិ៍សាត់ ក្រុមប្រឹក្សាក្រុងពោធិ៍សាត់ ស្រុកកណ្ដៀង ស្រុកបាកាន ស្រុកក្រគរ និងស្រុកភ្នំក្រវាញ គណៈអភិបាលក្រុងពោធិ៍សាត់ ស្រុកកណ្ដៀង ស្រុកបាកាន ស្រុកក្រគរ និងស្រុកភ្នំក្រវាញ និងក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៧កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងផែនការ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារកាលប្បវត្តិ